# MONTHLY REPORT | VOLUME 36

December 2024



**Project Activities:**

- 2nd Dec: Monthly Meeting with JICA HQ / Cambodia Office
- 3rd Dec: - Wrap-up Ceremony of In-Service Training
  - Meeting with new CCN President
- 9th Dec: Health Sector Meeting
- 12th Dec: 5th Joint Coordination Committee Meeting
- 17th-20th Dec: Training of Trainers in Battambang
- 24th-26th Dec: Training of Trainers in Kampong Cham

**សកម្មភាពគម្រោង៖**

- ថ្ងៃទី២ ខែធ្នូ៖ កិច្ចប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្ដាល JICA និង ការិយាល័យកម្ពុជា
- ថ្ងៃទី៣ ខែធ្នូ៖ - ពិធីបូកសរុបលទ្ធផលវគ្គបណ្ដុះបណ្ដាលក្នុងពេលបម្រើការងារ
  - កិច្ចប្រជុំជាមួយប្រធានគណៈគិលានុបដ្ឋាកកម្ពុជា
- ថ្ងៃទី៩ ខែធ្នូ៖ កិច្ចប្រជុំផ្នែកសុខាភិបាល
- ថ្ងៃទី១២ ខែធ្នូ៖ កិច្ចប្រជុំលើកទី ៥ របស់គណៈកម្មការសម្របសម្រួលគម្រោង
- ថ្ងៃទី១៧ ដល់ ២០ ខែធ្នូ៖ វគ្គបណ្ដុះបណ្ដាលក្នុងពេលបម្រើការងារ (បាត់ដំបង)
- ថ្ងៃទី២៤ ដល់ ២៦ ខែធ្នូ៖ វគ្គបណ្ដុះបណ្ដាលក្នុងពេលបម្រើការងារ (កំពង់ចាម)

## 5th Joint Coordination Committee (JCC) Meeting

## កិច្ចប្រជុំលើកទី ៥ របស់គណៈកម្មការសម្របសម្រួលគម្រោង

On the 12th of December, the 5th JCC meeting was held and chaired by H.E. Prof. THIR Kruy, Secretary of State of the Ministry of Health and Project Director. The purpose of this meeting was to: (1) report on project activity progress from May to November 2024, (2) finalize project design matrix (PDM) indicators, and (3) confirm the action plan for the next six months, including Training of Trainers (TOT) in two pilot provinces, Battambang and Kampong Cham. Additionally, there were reports on the completion and test launch of the e-learning platform, training course conducted for nursing managers from national hospitals, and evaluation and feedback collected from each training.

An active exchange of ideas regarding future trainings took place during the discussions. The project manager and project director encouraged PHDs along with CCN, to advance robust in these two pilot provinces.

ថ្ងៃទី ១២ ខែធ្នូ កិច្ចប្រជុំលើកទី ៥ របស់គណៈកម្មការសម្របសម្រួលគម្រោង ត្រូវបានប្រារព្ធឡើង និងដឹកនាំដោយ ឯកឧត្តម សាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជានាយកគម្រោង។ គោលបំណងនៃកិច្ចប្រជុំនេះគឺ៖ (១) ពិនិត្យរបាយការណ៍វឌ្ឍនភាពសកម្មភាពគម្រោងចាប់ពីខែឧសភា ដល់ខែវិច្ឆិកា ឆ្នាំ២០២៤ (២) បញ្ចប់សូចនាករម៉ាទ្រីសគម្រោង និង (៣) កំណត់ផែនការសកម្មភាពសម្រាប់រយៈពេលប្រាំមួយខែបន្ទាប់ រួមទាំងការបណ្ដុះបណ្ដាលនៅខេត្តសាកល្បងពីរ គឺខេត្តបាត់ដំបង និងខេត្តកំពង់ចាម។ លើសពីនេះ មានរបាយការណ៍ស្ដីពីការបញ្ចប់ និងធ្វើតេស្តសាកល្បងនៃវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ការបណ្ដុះ បណ្ដាលសម្រាប់ប្រធានគ្រប់គ្រងការថែទាំនៃមន្ទីរពេទ្យថ្នាក់ជាតិចំនួន១២ ការវាយតម្លៃវគ្គ និងមតិកែលម្អលើវគ្គបណ្ដុះបណ្ដាលនីមួយៗ។

ការផ្លាស់ប្ដូរគំនិតយ៉ាងសកម្មទាក់ទងនឹងការបណ្ដុះបណ្ដាលនាពេលអនាគតបានធ្វើឡើងក្នុងអំឡុងពេលពិភាក្សា។ អ្នកគ្រប់គ្រងគម្រោង និងនាយកគម្រោងបានលើកទឹកចិត្តដល់ មន្ទីរសុខាភិបាលរដ្ឋបាលខេត្ត រួមជាមួយអ្នកពាក់ព័ន្ធដើម្បីជំរុញគំនិតផ្ដួចផ្ដើមដ៏រឹងមាំនៅក្នុងខេត្តសាកល្បងទាំងពីរនេះ។




pictures during JCC meeting

## Wrap-up Ceremony of In-Service Training
## ពិធីបូកសរុបលទ្ធផលវគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារ





pictures during the ceremony

The Ministry of Health and JICA Strings project collaborated to hold the Wrap-up Ceremony for In-Service Training on December 3rd, 2024, at Calmette Hospital. The 8 courses which run from September 5th to November 1st, led by the Ministry of Health and supported by Strings project, were completed successfully by 24 nursing managers from 12 national hospitals in Cambodia.

Each representative of the hospital presented current activities and future training plans at their facilities. At the conclusion of the ceremony, H.E. Prof. IM Sethikar, Asst. Prof. TOUCH Sokneang, and Asst. Prof. KOY Virya from the Ministry of Health encouraged trainees to put what they had learned into practice, share it with their colleagues, and lead their teams as a role model.

ក្រសួងសុខាភិបាល និងគម្រោង Strings របស់ JICA សហការរៀបចំពិធីបូកសរុបលទ្ធផលបញ្ចប់វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ នៅមន្ទីរពេទ្យកាល់ម៉ែត។ វគ្គបណ្តុះបណ្តាលចំនួន ៨ បានដំណើរការចាប់ពីថ្ងៃទី ៥ ខែកញ្ញា ដល់ថ្ងៃទី ១ ខែវិច្ឆិកា ដែលដឹកនាំដោយក្រសួងសុខាភិបាល និងគាំទ្រដោយគម្រោងសហប្រតិបត្តិការបច្ចេកទេសរបស់ JICA ត្រូវបានបញ្ចប់ដោយជោគជ័យដែលមានប្រធានគ្រប់គ្រងការថែទាំចូលរួមចំនួន ២៤ នាក់មកពីមន្ទីរពេទ្យថ្នាក់ជាតិចំនួន ១២ នៅក្នុងប្រទេសកម្ពុជា។

តំណាងនៃមន្ទីរពេទ្យនីមួយៗ បានធ្វើបទបង្ហាញអំពីសកម្មភាពបច្ចុប្បន្ន និងផែនការបណ្តុះបណ្តាលនាពេលអនាគត នៅតាមអង្គភាពរបស់ពួកគេ។ នៅចុងបញ្ចប់នៃកម្មពិធីនេះ លោកជំទាវសាស្ត្រាចារ្យ អ៊ឹម សិទ្ធីការ៉ា លោកស្រីសាស្ត្រាចារ្យជំនួយ ទូច សុខនាង និងលោកសាស្ត្រាចារ្យជំនួយ កុយ វីរិយ៉ា នៃក្រសួងសុខាភិបាល បានលើកទឹកចិត្តដល់សិក្ខាកាមទាំងអស់ឱ្យយកអ្វីដែលពួកគេបានសិក្សាអំឡុងពេលបណ្តុះបណ្តាលយកទៅអនុវត្តន៍ ចែករំលែកចំណេះដឹងជាមួយសហការី និងដឹកនាំក្រុមរបស់ពួកគេជាគំរូ។

## Training of Trainers in Battambang and Kampong Cham
## វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅខេត្តបាត់ដំបង និងកំពង់ចាម



In December, training of trainers (ToT) was conducted with the support of provincial administrative health departments (PHD) in each pilot province, Battambang and Kampong Cham. Before the training started, the project team greeted and discussed with both respective PHDs. The first training kicked off in Battambang from the 17th until the 20th with 2 courses: Nursing Management & Leadership and Quality Improvement & Patient Safety. While the training in Kampong Cham for also 2 courses, Nursing Informatic and Nursing Research, took place from the 24th until the 26th. The current post-test results were considered satisfactory high with an average of over 90 percent, and the course evaluation by trainees also showed a relatively high level of satisfaction. The next ToT will continue in January 2025.

នៅក្នុងខែធ្នូ ឆ្នាំ២០២៤ ការបណ្តុះបណ្តាលគ្រូបង្គោលត្រូវបានធ្វើឡើងដោយមានការគាំទ្រពីមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តក្នុងខេត្តសាកល្បងនីមួយៗ បាត់ដំបង និងកំពង់ចាម។ មុនពេលវគ្គបណ្តុះបណ្តាលចាប់ផ្តើម ក្រុមការងារគម្រោងក៏បាន ពិភាក្សាជាមុនអំពីលក្ខខណ្ឌក្នុងការជ្រើសរើសសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ជាមួយមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តទាំងពីរ។ វគ្គបណ្តុះបណ្តាលលើកទី១ បានចាប់ផ្តើមនៅខេត្តបាត់ដំបង ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែធ្នូ ដែលមាន២វគ្គ៖ វគ្គការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ និងវគ្គការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺ នៅខេត្តបាត់ដំបង។ ខណៈដែលវគ្គបណ្តុះបណ្តាលនៅខេត្តកំពង់ចាមក៏មាន២វគ្គដូចគ្នាដែរ គឺវគ្គព័ត៌មានវិទ្យា នៃការថែទាំ និងវគ្គការស្រាវជ្រាវផ្នែកថែទាំ ដែលបាននៅធ្វើនៅថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែធ្នូ ។ ចំណែកលទ្ធផលតេស្តក្រោយវគ្គបច្ចុប្បន្នត្រូវបានចាត់ទុកថាពេញចិត្តខ្ពស់ជាមួយនឹងមធ្យមភាគជាង ៩០ ភាគរយ ហើយការវាយតម្លៃវគ្គសិក្សាដោយសិក្ខាកាមក៏បានបង្ហាញពីកម្រិតនៃការពេញចិត្តខ្ពស់ផងដែរ។ការបណ្តុះបណ្តាលបន្ទាប់នឹងបន្តនៅខែមករា ឆ្នាំ ២០២៥។



### UPCOMING ACTIVITIES
### សកម្មភាពនាពេលខាងមុខ

- 8th Jan: Monthly Meeting with JICA HQ / Cambodia Office
- 13th Jan: Health Sector Meeting
- 13th–17th Jan: ToT in Kampong Cham
- 14th–17th Jan: ToT in Battambang
- ថ្ងៃទី៨ ខែមករា៖ កិច្ចប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្តាល JICA និងការិយាល័យកម្ពុជា
- ថ្ងៃទី១៣ ខែមករា៖កិច្ចប្រជុំផ្នែកសុខាភិបាល
- ថ្ងៃទី១៣ ដល់ ១៧ ខែមករា៖ វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (កំពង់ចាម)
- ថ្ងៃទី១៤ ដល់ ១៧ ខែមករា៖ វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (បាត់ដំបង)

### CONTACT INFORMATION
**Project Office:**
- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2, Tuol Kork District, Phnom Penh, Cambodia
- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh, Cambodia
**Email: info@jicastrings.com**



JICA's FB Page

Project's Homepage